**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៤១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលមាត្រា ៩ និងមាត្រា ១៣ នៃអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រាមួយ .-**

មាត្រា ៩ និងមាត្រា ១៣ នៃអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ត្រូវបានកែសម្រួលដូចតទៅ ÷

**មាត្រា ៩ .- ថ្មី**

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវចេញសេចក្តីជូនដំណឹងស្តីពីកាលបរិច្ឆេទនៃការកំណត់ព្រំដីទៅអ្នកដាក់ពាក្យស្នើសុំ និងត្រូវបិទផ្សាយជាសាធារណៈក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃ យ៉ាងតិចមុនកាលបរិច្ឆេទនៃការកំណត់ព្រំដី នៅសាលាក្រុង ស្រុក ខណ្ឌ សាលាឃុំសង្កាត់ និងនៅទីកន្លែងដែលងាយមើលឃើញក្នុងភូមិដែលក្បាលដីស្នើសុំចុះបញ្ជីនោះស្ថិតនៅ។

**មាត្រា ១៣ .- ថ្មី**

បន្ទាប់ពីការពិនិត្យភាពច្បាស់លាស់ខាងបច្ចេកទេស រដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ ត្រូវចុះហត្ថលេខាលើទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី។

ឯកសារនៃការវិនិច្ឆ័យដែលត្រូវផ្សព្វផ្សាយ រួមមាន ផែនទីក្បាលដី គំនូសបង្ហាញទីតាំងដី និងបញ្ជីឈ្មោះម្ចាស់ដី។ ការផ្សព្វផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យត្រូវធ្វើឡើងក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៅសាលាក្រុង ស្រុក ខណ្ឌដែលមានសមត្ថកិច្ច។ សេចក្តីចម្លងនៃឯកសារទាំងនេះ ក៏ត្រូវបិទផ្សាយផងដែរ នៅទីស្នាក់ការឃុំ សង្កាត់ដែលក្បាលដីស្នើសុំចុះបញ្ជីនោះស្ថិតនៅ។

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវជូនដំណឹងអំពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យនេះដល់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីដី។ សេចក្តីជូនដំណឹងត្រូវធ្វើឡើងយ៉ាងតិច ៣ (បី) ថ្ងៃ មុនថ្ងៃបើកការផ្សព្វផ្សាយជាសាធារណៈ ហើយត្រូវបិទផ្សាយនៅកន្លែងដែលងាយមើលឃើញនៅក្នុងភូមិ នៅសាលាឃុំ សង្កាត់ និងនៅសាលាក្រុង ស្រុក ខណ្ឌ។

**មាត្រាពីរ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

<u>កន្លែងទទួល</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ